ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៤៣

ចុះថ្ងៃទី:១៦-៥-២០០៨

សាលដីកា

លេខ : ១១៩ "ខ"

ចុះថ្ងៃទី:០៨-៩-២០០៩

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៩ ដោយមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៤៣ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៨ រវាង

១. ជនជាប់ចោទឈ្មោះ [redacted] អ៊ិយ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើត និងទីលំនៅមុនចាប់ខ្លួន [redacted] ឃុំត្រពាំងសាលាខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកឈ្មោះអ៊ិន ម្តាយឈ្មោះស្រ៊ុន ទោសពីមុនគ្មាន មេធាវីលោកកែត ឃី

២. ជនជាប់ចោទឈ្មោះ [redacted] រី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនិងទីលំនៅមុនចាប់ខ្លួ[redacted] ខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកឈ្មោ[redacted]រ" ម្តាយឈ្មោះ[redacted]រ" ទោសពីមុនគ្មាន នៅក្នុងឃុំ មេធាវី[redacted] ឃី

៣. ជនជាប់ចោទឈ្មោះ [redacted] លុច ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើត និងទី[redacted] ឃុំត្រពាំងសាលាខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន មេធាវី លោក[redacted] ឃី ។

៤. ជនជាប់ចោទឈ្មោះ[redacted] ឈាន ហៅ ឡាត ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ កើត នឹងទីលំនៅសព្វថ្ងៃ [redacted] ស្រុកបន្ទាយមាស ខេត្តកំពត។ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ[redacted] កន (ស) ទោសពីមុនមានសាលក្រមកំបាំងមុខ ៦ឆ្នាំរបស់តុលាការខេត្តកំពត បច្ចុប្បន្នគេចខ្លួន មេធាវីលោក[redacted] ឃី ។

<u>ត្រូវចោទពីបទៈ</u> " ប្លន់ទ្រព្យសម្បត្តិពលរដ្ឋ " ប្រព្រឹត្តនៅភូមិល្បៀប ឃុំត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី២៦-០១-២០០៦ បទល្មើសមានចែង ឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

- តាមបណ្តឹងឧទ្ធរណ៍លេខ ៤៥ ចុះថ្ងៃទី ២១-០៨-២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] លុច ស្តីពីឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៣ ចុះថ្ងៃទី ០៧-០៨-២០០៧ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចទាំងមូល ។

# ដំណើររឿងមានដូចតទៅ

ជនល្មើសមួយក្រុមមានគ្នា ០៤នាក់ ឈ្មោះ[redacted] អិយ, ឈ្មោះ [redacted] ឈាន ហៅ ឡាត, ឈ្មោះ [redacted]រី និង ឈ្មោះ [redacted] លុច តែងធ្វើសកម្មភាពដាក់ថ្នាំបំពុលឆ្កែ ចូលប្លន់ទ្រព្យសម្បត្តិដូចជា ម៉ូតូរបស់ប្រជាពលរដ្ឋ ជាច្រើនលើក ។

ជាក់ស្តែងនៅយប់ថ្ងៃទី ២១-០១-២០០៦ ជនល្មើស ០១ក្រុម មានឈ្មោះ [redacted] លុច មានម៉ូតូ បានដឹកបក្សពួកខ្លួនឈ្មោះ [redacted] អិយ, [redacted] រី, [redacted] ឈាន ភ្ជាប់ដោយសាច់លាយថ្នាំបំពុល ធ្វើសកម្មភាពបំពុលឆ្កែងាប់អស់ ០២ក្បាល នៅផ្ទះជនរងគ្រោះឈ្មោះ [redacted]អេង យកបានម៉ូតូ ០១គ្រឿងម៉ាកហុងដា ១០០ ពណ៌ក្រហម ផលិតនៅប្រទេសកូរ៉េ យកទៅលក់នៅក្រុងភ្នំពេញបានប្រាក់ចំនួន ១៥០$ ចែកគ្នាចាយអស់ ។ ក្រោយពេល ប្រព្រឹត្តជនល្មើសគេចខ្លួនបាត់ដូចមុន តែជនល្មើសមានសាវតាជាតិគ្រប់គ្រាន់ តុលាការបានចេញដីកាចាប់ខ្លួនជាបន្តបន្ទាប់ ជាក់ស្តែងជនល្មើស [redacted] អិយ ត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅខេត្តតាកែវ ។ ចំណែកឈ្មោះ [redacted] រី និង[redacted] លុច ត្រូវសមត្ថកិច្ចចាប់ខ្លួនតាមដីកាលេខ ១៥៤, ១៥៥ ចុះថ្ងៃទី១១-១០-០៦ ពាក់ពន្ធ័ទៅនឹងបទល្មើសខាងលើ ។ ឈ្មោះ [redacted] ឈាន គេចខ្លួន មានដីកាចាប់ខ្លួនលេខ ៧១ ចុះថ្ងៃទី ០៨-០២-២០០៧ ក្នុងបទល្មើសមុនហើយ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១០៣ ចុះថ្ងៃទី ០៧-០៨-២០០៧ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារ និងសេចក្តីសំរេចដូចតទៅ ៖

១. ផ្តន្ទាទោស

ក. ឈ្មោះ[redacted] លុច ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ ( ប្រាំពីរឆ្នាំ) គិតពីពេលចាប់ខ្លួន

ខ. ឈ្មោះ [redacted] អិយ ភេទប្រុស អាយុ២៣ឆ្នាំ និង[redacted] ឈាន ហៅ ឡាត ភេទប្រុស អាយុ៤០ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ ០៨ឆ្នាំ ចំពោះ [redacted] អិយ គិតបន្តពីការអនុវត្តទោសរបស់តុលាការខេត្តតាកែវរួច ឯ [redacted] ឈាន ហៅ ឡាត គិតពីថ្ងៃចាប់ខ្លួនបាន.

គ. ឈ្មោះ[redacted]រី ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ( ប្រាំឆ្នាំ ) គិតពិថ្ងៃចាប់ខ្លួន.

- ចំណុច ក.ខ.គ ពីបទ " ប្លន់ " ប្រព្រឹត្តនៅភូមិ លៀប ឃុំត្រពាំងសាលាខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី២១-០១-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២. អោយឈ្មោះ [redacted] អិយ, [redacted] លុច, [redacted] រី និង[redacted] ឈាន ហៅឡាត រួមគ្នាសងសំណងចំនួន ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅជនរងគ្រោះ [redacted]អេង ចាប់ពីពេលសាលក្រមនេះស្ថាពរ សំណើរលើសពីនេះត្រូវលើកចោល ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅតុលាការខេត្តកំពត សំរេចសេចក្តីចំពោះមុខ នៅថ្ងៃទី០៧-៨-២០០៧ និងបើកសិទ្ធិអោយភាគីដែលអវត្តមាន ប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសាលក្រម កំបាំងមុខនេះ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០២ខែ គិតពីថ្ងៃផុតប្តឹងទាស់ ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

## ដំណើរសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] អ៊ិយ, [redacted] ឈាន, [redacted] លុច និង [redacted] រី បានឆ្លើយនៅតុលាការខេត្តកំពត ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តាមចំលើយសារភាពរបស់ជនត្រូវចោទឈ្មោះ [redacted] អ៊ិយ, [redacted] លុច និង [redacted] រី ព្រមទាំងជនរងគ្រោះ ឃើញថាមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកដូចការចោទប្រកាន់តំណាងអយ្យការមែន គួរតម្កល់សាលក្រមទុកជា បានការ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ [redacted] អ៊ិយ, [redacted] លុច និង [redacted] រី ព្រមទាំងជនរងគ្រោះ ឃើញថាមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកដូចការចោទប្រកាន់របស់តំណាងអយ្យការមែន, សូមក្រុមប្រឹក្សាតម្កល់សាលក្រមទុកជាបានការ

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា

១- បណ្តឹងឧទ្ធរណ៍លេខ ៤៥ ចុះថ្ងៃទី ២១-០៨-២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] លុច ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- កាលពីថ្ងៃទី ២១-០១-២០០៦ ជនល្មើស០១ក្រុម មានគ្នា ០៤នាក់ គឺ ឈ្មោះ [redacted] លុច, [redacted] អ៊ិយ, [redacted] រី និង [redacted] ឈាន ដោយមានសាច់លាយថ្នាំពុលផង បានធ្វើសកម្មភាពបំពុលឆ្កែនៅផ្ទះជនរងគ្រោះ ងាប់អស់ ០២ក្បាល ចូលយកម៉ូតូម៉ាក C100 ផលិតនៅប្រទេសកូរ៉េ របស់ជនរងគ្រោះ យកទៅលក់នៅភ្នំពេញបានប្រាក់ ១៥០ដុល្លារ US ចែកគ្នាចាយ ។

៣- តាមចម្លើយជនជាប់ចោទថា ខ្លួនធ្លាប់ដឹកក្រុមជនជាប់ចោទនេះ០៦លើកមកហើយ តែពួកវាមិនបាន ប្រាប់ខ្លួនថាទៅបំពុលឆ្កែគេទេ ។ ខ្លួនស្គាល់ [redacted] អ៊ិយ, [redacted] រី និង [redacted] ឈាន ប្រាកដមែន ។

៤- មានពិរុទ្ធលើជនជាប់ចោទពីបទប្លន់ ប្រព្រឹត្តនៅភូមិលៀប ឃុំត្រពាំងសាលាខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី២១-០១-២០០៦ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១០៣ ចុះថ្ងៃទី ០៧-០៨-២០០៧ របស់សាលាដំបូងខេត្តកំពត សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៥ ចុះថ្ងៃទី ២១-០៨-២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] លុច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់,

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០៣ ចុះថ្ងៃទី ០៧-០៨-២០០៧ របស់សាលាដំបូងខេត្តកំពត ទុកជាបានការពេញទាំងមូល.

៣. បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹង បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ភ្នំពេញ ថ្ងៃទី 30 ខែ 12 ឆ្នាំ២០១០
ក្រឡាបញ្ជី